# ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៥០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានទ្រង់យល់ **សម្តេច ជា ស៊ីម** ជាអគ្គមគ្គុទេសក៍ដ៏វិសេសវិសាល ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់ របស់ប្រជារាស្ត្រ បានដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បានកសាងប្រព័ន្ធច្បាប់ សំរាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ ការអភិវឌ្ឍន៍ជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ។
- បានទ្រង់យល់ **សម្តេច ជា ស៊ីម** ជាអគ្គមគ្គុទេសក៍ដ៏វិសេសវិសាល ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់ របស់ប្រជារាស្ត្រ បានចូលរួមដឹកនាំកសាង និងគោរពព្រះពុទ្ធសាសនា និងសាសនាផ្សេងៗទៀត ឱ្យមានការរីកចំរើន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់ **សម្តេច ជា ស៊ីម** ជាអគ្គមគ្គុទេសក៍ដ៏វិសេសវិសាល ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់ របស់ប្រជារាស្ត្រ មានស្មារតីភក្តីចំពោះរាជបល្ល័ង្ក ការពារនិរន្តរភាពរាជានិយម នៃព្រះរាជាណាចក្រកម្ពុជា ។

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

## ប្រោសព្រះរាជទានគោរមងារ

លេខ : ០៣១/...
រាជធានីភ្នំពេញ, ថ្ងៃទី ១... ខែ ... ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរវៀងជ័យ ...
ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

## សម្តេច ជា ស៊ីម

ជា

## សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៣៤.០៧១០.៥២៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៧